ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ
វិទ្យាល័យ អង្គរកា

## ចូលរួមអបអរសាទរទិវាអំណាន
លើប្រធានបទ

# តួនាទីអក្សរសិល្ប៍ក្នុងសង្គម

គ.ស. ២០២០


ឈ្មោះ **យ៉ែម មករា** ភេទ ប្រុស
ទីកន្លែងធ្វើការៈ វិទ្យាល័យ អង្គរកា
លេខទូរស័ព្ទៈ ០១៥ ៤២ ៨២ ៤២/ ០១២ ៣២ ២៤ ៦៦

## សេចក្តីផ្តើម

អក្សរសិល្ប៍ ជាសមិទ្ធផលមួយដែលកើតចេញពីពលកម្មពិតៗរបស់មនុស្ស។ អក្សរសិល្ប៍ផ្សារភ្ជាប់នឹងពលកម្មនៅក្នុងសម័យកាលមួយយ៉ាងវែងនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ[1]។ ពីមួយដំណាក់កាលទៅមួយដំណាក់កាល ស្នាដៃអក្សរសិល្ប៍មានការវិវត្តឥតឈប់ឈរ។ ចាប់ផ្តើមពីការបកស្រាយលើបាតុភូតធម្មជាតិ អក្សរសិល្ប៍បានបង្វែរនិន្នាការរបស់ខ្លួនមកបង្ហាញពីតថភាពនានាដែលមាននៅក្នុងបទពិសោធន៍ជីវិតជាក់ស្តែងរបស់មនុស្ស។ តាមរយៈរបត់នៃការផ្លាស់ប្តូរនេះ ស្នាដៃអក្សរសិល្ប៍នីមួយៗលែងស្ថិតនៅក្រោមឥទ្ធិពលនៃសាសនា ឬបង្ហាញនូវភាពវេទវាយណាមួយទៀតឡើយ ផ្ទុយទៅវិញអក្សរសិល្ប៍ទាំងឡាយចាប់ផ្តើមធ្វើការបរិយាយរៀបរាប់ពីអ្វីដែលជាភាពពិតប្រាកដ ជុំវិញការរស់នៅជាក់ស្តែងរបស់មនុស្សប្រកបទៅដោយសិល្បៈបារម្មណ៍យ៉ាងរស់រវើក។

ភាពប្រាកដនិយមថ្មីនេះ បានឆ្លុះបញ្ចាំងឱ្យយើងឃើញនូវគុណតម្លៃ និងតួនាទីយ៉ាងសំខាន់របស់ស្នាដៃអក្សរសិល្ប៍នីមួយៗ ដែលមិនត្រឹមតែជាគ្រឿងកែកម្សាន្ត បង្កឱ្យមានភាពសប្បាយរីករាយសម្រាប់មនុស្សតែប៉ុណ្ណោះទេ តែវាក៏បានចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍសង្គមឆ្ពោះទៅរកភាពរីកចម្រើនដូចគ្នា។ ខាងក្រោមនេះ គឺជាការឆ្លុះបញ្ចាំងនូវតួនាទីចម្បងមួយចំនួនរបស់ស្នាដៃអក្សរសិល្ប៍នៅក្នុងសង្គមនាពេលបច្ចុប្បន្ន។

### ១. **អ្វីជាអក្សរសិល្ប៍**?

តាមរយៈការសិក្សាទូទៅលើនិយមន័យរបស់ពាក្យថា "អក្សរសិល្ប៍" យើងសង្កេតឃើញមានទស្សនៈយល់ឃើញប្លែកៗពីគ្នា តួយ៉ាងដូចជា៖

- តាមវាក្យសព្ទ "អក្សរសិល្ប៍ < អក្សរ + សិល្ប៍"

  អក្សរ សំដៅដល់ស្នាមគំនូសផ្សេងៗដែលយើងប្រើប្រាស់នៅក្នុងការកត់សូរភាសា។

  សិល្ប៍ សំដៅដល់រូបារម្មណ៍ វិធី ឬបែបបទដែលប្រកបទៅដោយសិល្បៈ[2]។

ដូចនេះ អក្សរសិល្ប៍ គឺជាស្នាមគំនូស ឬជាកម្រងអត្ថបទពាក្យរាយឬពាក្យកាព្យទាំងឡាយណាដែលកើតចេញអំពីសមត្ថភាពទេពកោសល្យរបស់អ្នកនិពន្ធ បង្កើតបានជាសាច់រឿងប្រកបទៅដោយសិល្បៈរូបារម្មណ៍នាំឱ្យអ្នកអានអ្នកស្តាប់ទាំងឡាយជក់ចិត្តជិតអារម្មណ៍ ចង់តាមដានហើយតាមដានទៀតមិនចេះជិនណាយ។

- តាមទស្សនៈលោកជ័យ ចាប និងពន់ ឆាយ យល់ថា "អក្សរសិល្ប៍ គឺជាសិល្បៈនៃការសម្តែងតាមអក្សរ ឬការប្រើអក្សរដើម្បីបញ្ចេញទស្សនៈ ឬចក្ខុសម្ផស្ស[3]"។
- តាមទស្សនៈលោកកេង វ៉ាន់សាក់ លើកឡើងថា "អក្សរសិល្ប៍ គឺជាវិទ្យាស្សង់មួយដែលបានលើកយកបញ្ហារបស់មនុស្សមកចោទ និងដោះស្រាយទៅតាមសិល្បវិធី និងទៅតាមសង្គមនីមួយៗ"។

---

[1] ក្រសួងអប់រំ *អក្សរសិល្ប៍ខ្មែរថ្នាក់ទី៨* ដោយ អ៊ីវ ចុង ១៩៨៥

[2] សម្តេចសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរ* ១៩៦៧

[3] ជ័យចាប និងពន់ ឆាយ *ទ្រឹស្តីអក្សរសិល្ប៍* ១៩៩៤

- តាមទស្សនៈរបស់លោកម៉ាក់ស៊ីម គ័រគី (Maxime Gorky) ជនជាតិរុស្ស៊ី លោកបានអះអាងថា "អក្សរសិល្ប៍ គឺជាមនុស្សវិជ្ជា"។
- តាមទស្សនៈលោក ប៊ីយេនសិនស្គី ជនជាតិរុស្ស៊ី បានយល់ថា "អក្សរសិល្ប៍ជាកម្រងឯកសារនៃជីវិត"។
- តាមទស្សនៈរបស់លោក ម៉ាក្ស លេនីន (Marx Lenine) យល់ថា "អក្សរសិល្ប៍ ជាមធ្យោបាយដ៏ស្រួចស្រាវបំផុតសម្រាប់យល់ដឹងអំពីតថភាពជាក់ស្តែង និងជាកត្តាមួយសំខាន់ចំពោះជីវភាពសង្គម"។
- តាមទស្សនៈរបស់លោក សង់ ប៉ូលសាត្រ ជនជាតិបារាំង បាននិយាយថា "អក្សរសិល្ប៍គឺជាការអធិប្បាយផ្សាយចិត្តគំនិតរបស់អ្នកនិពន្ធ"។
- តាមទស្សនៈលោកអេថែន ឡាប្លេនី (E. Lablenie) ជនជាតិអាល្លឺម៉ង់ យល់ថា "អក្សរសិល្ប៍គឺជាមែកធាងមួយនៃសិល្បៈ ព្រោះគេយកតួអក្សរមកធ្វើជាសិល្បៈ រចនាបានជាប្រភេទស្នាដៃផ្សេងៗដូចជា អត្ថបទពាក្យរាយ អត្ថបទកាព្យ អត្ថបទល្ខោនជាដើម"។

នៅលើនិយមន័យទាំងឡាយដែលយើងបានបង្ហាញខាងលើនេះ ពុំមានខ្លឹមសារអ្វីខុសគ្នាខ្លាំងនោះទេ។ យ៉ាងហោចណាស់យើងក៏សង្កេតឃើញថា រាល់និយមន័យទាំងឡាយ អ្នកសិក្សានានាបានផ្តោតសំខាន់លើកត្តាចំនួនពីរ ពោលគឺតថភាពសង្គម និងសិល្បវិធីរបស់អ្នកនិពន្ធ។

**២. សំនុំមូលដ្ឋាននៃអក្សរសិល្ប៍**

ចំពោះទស្សនៈទាំងឡាយដែលយល់ថា អក្សរសិល្ប៍ ចាប់ប្រភពពីសភាវៈលំហែកម្សាន្ត ឬចាប់ប្រភពពីសាសនាអាចជាទស្សនៈមិនត្រឹមត្រូវ និងមានគ្រោះថ្នាក់ ព្រោះទស្សនៈមួយនេះយល់ត្រឹមតែ "អក្សរសិល្ប៍ បម្រើឱ្យតែអក្សរសិល្ប៍" ដែលជាទំនោរប្រតិកិរិយាក្នុងលក្ខខណ្ឌអក្សរសិល្ប៍សិល្បៈ។ មូលដ្ឋានចាំបាច់នៃអក្សរសិល្ប៍ស្តែងឡើងតាមរយៈរូបភាពចំនួន៣ ពោលគឺៈ

**ក. សច្ចៈ**

រាល់កម្រងស្នាដៃអក្សរសិល្ប៍ទាំងឡាយចាំបាច់ត្រូវតែផ្សារភ្ជាប់ជាមួយនឹងតថភាព ឬភាពពិតជាក់ស្តែងដែលមាននៅក្នុងសង្គម។ យើងដឹងថា អក្សរសិល្ប៍ជាបន្សំរវាងសច្ចភាព និងសិល្បរូបារម្មណ៍ ដែលក្នុងនោះ អ្នកនិពន្ធអាចមានលទ្ធភាពបង្កើតឱ្យមានតថភាពយ៉ាងសម្បូរបែបក្នុងស្នាដៃនីមួយៗ។ ត្បិតថាអក្សរសិល្ប៍ពុំមែនជាប្រវត្តិសាស្ត្រទាំងស្រុង តែវាក៏ជាផ្នែកមួយសំខាន់ដែលអាចឱ្យមនុស្សធ្វើការសិក្សាពីប្រវត្តិសង្គមក្នុងសម័យកាលណាមួយបានជាក់លាក់ផងដែរ។ ក្នុងន័យនេះ សច្ចៈ ត្រូវបានអ្នកនិពន្ធប្រើប្រាស់នៅក្នុងការបង្កើតស្នាដៃអក្សរសិល្ប៍ខ្មែរនានា បើទោះបីជានៅក្នុងប្រភេទស្នាដៃអក្សរសិល្ប៍បុរាណដូចជា អត្ថបទបែបព្រាហ្មណ៍និយម ឬពុទ្ធនិយមក៏ដោយ ក៏ក្នុងនោះយើងសង្កេតឃើញថាកវីនិពន្ធខ្មែរពុំបាន បោះបង់ចោលនូវតថភាពឡើយ។ ផ្ទុយទៅវិញអ្នកនិពន្ធទាំងឡាយនោះបានព្យាយាមផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅជាក់ស្តែងរបស់មនុស្ស ហើយតាមសកម្មភាពនេះពួកគេអាចរក្សាបាននូវខ្លឹមសាររឿង ដែលមិនមានភាពប្រឌិតជ្រុលហួសហេតុពេក។ ជាឧទាហរណ៍ជាក់ស្តែង ការប្រឌិតឱ្យមានស្នឹងសង្កែហូរកាត់ទីក្រុងភ្នំពេញ ឬនារីស្រុកស្រែធ្វើការមាំមួនក្នុងស្រែដូចជា

បុរសតែបែរជាមានម្រាមដៃទន់ល្មើយដូចសំឡីជាដើម គឺជាការប្រឌិតដែលខ្វះសច្ចភាពទាំងស្រុង ជាហេតុនាំឱ្យស្នាដៃទាំងនោះពុំអាចយកជាការ ឬទុកជាឯកសារពិគ្រោះសម្រាប់អ្នកសិក្សាជំនាន់ក្រោយបាននោះឡើយ[4]។

**ខ. កុសល**

ការអប់រំ គឺជាមូលដ្ឋានសំខាន់មួយសម្រាប់ស្នាដៃអក្សរសិល្ប៍នីមួយៗ។ ក្នុងនោះ អក្សរសិល្ប៍ត្រូវបានគេចាត់ទុកជាសាលាបណ្តុះនូវចំណេះដឹងនិងសីលធម៌។ អាស្រ័យដោយហេតុនេះ អក្សរសិល្ប៍ចាំបាច់ត្រូវតែបង្ហាញឱ្យឃើញនូវការអប់រំផ្នែកបញ្ញាស្មារតី ក៏ដូចជាការអប់រំផ្នែកសីលធម៌ដល់អ្នកអានអ្នកសិក្សា ក៏ដូចជាហែសាធុជនទូទៅផងដែរ។ ដូចអ្វីដែលយើងបានរៀបរាប់មកខាងលើ អក្សរសិល្ប៍មិនមែនបង្កើតឡើងដើម្បីតែភាពសប្បាយរីករាយតែម្យ៉ាងប៉ុណ្ណោះទេ តែត្រូវធ្វើយ៉ាងណាឱ្យអ្នកអានអ្នកស្តាប់ទាំងឡាយទទួលបាននូវសារៈប្រយោជន៍ អាចពង្រឹងការគិត ការវិភាគ និងត្រិះរិះលើបញ្ហាសង្គមនានាប្រកបទៅដោយប្រសិទ្ធភាព។ តាមរយៈខ្លឹមសារនេះ អក្សរសិល្ប៍ មានលទ្ធភាពអាចធ្វើឱ្យមនុស្សសើចនៅភ្នែកម្ខាងហើយយំនៅភ្នែកម្ខាងទៀត មានន័យថាបន្ទាប់ពីបានសើចសប្បាយ មនុស្សក៏អាចមានលទ្ធភាពនៅក្នុងការត្រិះរិះលើខ្លឹមសារដែលអ្នកនិពន្ធចង់បង្ហាញដូចគ្នា។

តួយ៉ាងតាមរយៈអត្ថបទរឿងធនញ្ជ័យ ក្រៅពីការសើចសប្បាយជាមួយនឹងសកម្មភាពតួអង្គយើងអាចមើលឃើញពីគំនិតរិះគន់សង្គមដែលជាតម្លៃអប់រំយ៉ាងជ្រាលជ្រៅរបស់អ្នកនិពន្ធ។ យ៉ាងណាមិញ អត្ថបទរឿងអាជ័យមីរត បង្ហាញតែនូវសំណើចបែបរិះគន់ ស្របតាមមនោគមពួកអភិជន ខ្វះមូលដ្ឋានអប់រំ បានក្លាយទៅជាស្នាដៃប្រតិកិរិយា មិនទទួលបានការគាំទ្រពីអ្នកសិក្សាទូទៅ។

**គ. សោភ័ណ**

ស្នាដៃអក្សរសិល្ប៍មិនដូចស្នាដៃនៃវិទ្យាសាស្ត្រនោះទេ ដោយហេតុថាស្នាដៃអក្សរសិល្ប៍ចាំបាច់ត្រូវតែប្រើប្រាស់នូវសោភ័ណ ដែលជាសិល្បារម្មណ៍ដើម្បីសម្រេចបាននូវមុខងារអប់រំផ្សេងៗ។ អក្សរសិល្ប៍មានកម្លាំងអស្ចារ្យខាងបញ្ចុះបញ្ចូល ពោលគឺការអប់រំមនុស្សតាមរយៈសោភ័ណសិល្បៈ។ ការប្រើប្រាស់នូវសោភ័ណ ឬសិល្បវិធីទាំងនេះ វាមានឥទ្ធិពលខ្លាំងណាស់ទៅលើសញ្ចេតនារបស់មនុស្ស។ សោភ័ណនេះអាចមានសមត្ថភាពភ្ញោច ឬកន្ត្រាក់អារម្មណ៍យើងឱ្យមានសញ្ចេតនារំភើប ពោរពេញទៅដោយសេចក្តីប្រាថ្នា និងការស្រមៃ ចំពោះជីវិតបច្ចុប្បន្ន និងអនាគត។ ហេតុនេះ ស្នាដៃអក្សរសិល្ប៍ពុំអាចរុញច្រានចោលនូវសិល្ប៍សោភ័ណនេះបានឡើយ បើពុំនោះសោតអក្សរសិល្ប៍ទាំងនោះក៏មិនអាចក្លាយខ្លួនជាទីចាប់អារម្មណ៍របស់មនុស្សបានដូចគ្នា។ ជាក់ស្បាន់ នៅក្នុងរឿងស៊ឹមអ្នកបរឡាន ក៏ដូចជារឿងគ្រូបង្រៀនស្រុកស្រែជាដើម រឿងទាំងពីរនេះមានតែសាច់ការ គ្មានលក្ខណៈសិល្បៈ នាំឱ្យគេមិនសូវជានិយមចូលចិត្តអាន។ ទាំងនេះគឺជាភស្តុតាងដែលស្តែងឱ្យយើងមើលឃើញកាន់តែច្បាស់ថា

[4] នគ ហង្សផល្លា *ភាពថ្លៃថ្នូមានក្នុងអក្សរសិល្ប៍ខ្មែរ* ២០១០

ស្នាដៃអក្សរសិល្ប៍ចាំបាច់ត្រូវតែមានសិល្ប៍សោភ័ណជាចាំបាច់ ទើបអាចទាញអារម្មណ៍អ្នកអានអ្នកស្ដាប់ឱ្យជក់ចិត្តជិតអារម្មណ៍នឹងតាមដានអត្ថបទរបស់ខ្លួនបាន[5]។

## ៣. តួនាទីអក្សរសិល្ប៍ក្នុងសង្គម

### ក. តួនាទីនៅក្នុងការអប់រំបណ្ដុះបណ្ដាលមនុស្ស

អក្សរសិល្ប៍មានតួនាទីសំខាន់ណាស់នៅក្នុងការអប់រំ និងបណ្ដុះស្មារតីមនុស្ស។ ក្នុងន័យនេះ អក្សរសិល្ប៍ត្រូវបានគេចាត់ទុកជាវិស្វករនៃដួងចិត្ត ដែលក្នុងនោះអក្សរសិល្ប៍មិនត្រឹមតែបង្ហាញនូវជីវិតថ្មី មនុស្សថ្មីនោះទេ ថែមទាំងបានចូលរួមយ៉ាងសកម្មនៅក្នុងការកសាង និងអប់រំមនុស្សថ្មីទៀតផង។ ខាងក្រោមនេះគឺជាគោលការណ៍សំខាន់ចំនួនបួន ដែលបង្ហាញអំពីការចូលរួមរបស់អក្សរសិល្ប៍នៅក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស។

#### ក.១. វិជ្ជាសម្បទា

អក្សរសិល្ប៍ ត្រូវផ្ដល់ឱ្យអ្នកអាន អ្នកទស្សនានូវបញ្ញត្តិ ចំណេះដឹង ពុទ្ធិទាក់ទងនឹងជីវភាពរស់នៅជាក់ស្ដែងរបស់មនុស្ស។ ជារឿយៗយើងតែងតែប្រទះឃើញនូវប្រព័ន្ធមេរៀនល្អៗស្ដីពីជីវិតសម្រាប់មនុស្សតាមរយៈស្នាដៃអក្សរសិល្ប៍នានា។ មេរៀនទាំងនោះភាគច្រើនមានផ្សារភ្ជាប់ទៅនឹងធម្មជាតិ និងក្រឹតក្រមទាំងឡាយនៃជីវភាពរស់នៅពិតប្រាកដ រួមមានជំនឿ សាសនា ការគោរពបូជា ទំនៀមទម្លាប់ប្រពៃណី ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ស្នេហា សង្គ្រាម នយោបាយ ការគ្រប់គ្រង និងបច្ចេកវិទ្យាទំនើបៗនានាផងដែរ ដូចអ្វីដែលលោកឈៃនីឆូវស្គីបានពោលថា "អក្សរសិល្ប៍ គឺជាសៀវភៅសិក្សាអំពីជីវិត"។ ចំណុចទាំងអស់នេះចាត់ទុកជាពុទ្ធិថ្មីៗសម្រាប់អ្នកអានអ្នកសិក្សាទាំងឡាយ បើទោះបីជាពួកគេនៅក្នុងសម័យបច្ចុប្បន្ន យ៉ាងហោចណាស់ក៏ពួកគេអាចស្វែងយល់ពីតថភាពក្នុងអតីតកាល ក៏ដូចជាស្វែងយល់ពីទស្សនៈវិស័យនាពេលអនាគត តាមរយៈការបង្ហាញរបស់អ្នកនិពន្ធផងដែរ។

តួយ៉ាងដូចជានៅក្នុងអត្ថបទរឿងទុំទាវ ដែលជាស្នាដៃរបស់ព្រះបទុមត្ថេរសោមជាដើម។ ក្នុងរឿងនេះ អ្នកសិក្សាទាំងឡាយអាចទទួលជ្រាបនូវពុទ្ធិថ្មីជាច្រើនទាក់ទងទៅនឹងសង្គមខ្មែរនាសម័យលង្វែក។ ក្រៅពីការកម្សាន្តរីករាយជាមួយសិល្បវិធីរបស់អ្នកនិពន្ធ អ្នកសិក្សាទាំងឡាយអាចស្វែងយល់អំពី៖

- ការគ្រប់គ្រងៈ ការគ្រប់គ្រងសង្គមនាសម័យនោះមានលក្ខណៈផ្ដាច់ការ តាំងពីថ្នាក់ក្រោមដល់ថ្នាក់លើ។ គិតរាប់ចាប់ពីការគ្រប់គ្រងក្នុងគ្រួសារទៅ យើងឃើញថាម្ដាយទាវប្រើប្រាស់ភាពផ្ដាច់ការទាំងស្រុងក្នុងការបង្ខំទាវឱ្យរៀបការជាមួយម៉ឺនងួន។ រីឯអរជូនដែលជាអ្នកគ្រប់គ្រងថ្នាក់ខេត្តថ្នាក់តំបន់វិញ ប្រើប្រាស់អំណាចកាប់សម្លាប់មនុស្សដោយចិត្តឯង គ្មានបើកការកាត់ក្ដីឱ្យបានត្រឹមត្រូវសោះឡើយ។ ដោយឡែក ព្រះរាជាដែលជាស្ដេចគ្រប់គ្រងផែនដី ក៏បានប្រើប្រាស់អំណាចផ្ដាច់ការរបស់ខ្លួនក្នុងការដាក់ទោសគ្រួសារអរជូន ម្ដាយទាវ ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតដែលគ្មានកំហុសយ៉ាងព្រៃផ្សៃ។

[5] ជុំ យុនសុជាតា *ប្រវត្តិអក្សរសិល្ប៍* ២០១៣

- សេដ្ឋកិច្ចៈ ការជួញដូរ តួយ៉ាងយើងសង្កេតឃើញថាព្រះសង្ឃនាសម័យនោះមានទុំនិងពេជ្រជាដើម បានសុំព្រះចៅអធិការចេញទៅស្រុកឆ្ងាយដើម្បីលក់តោក។
- វប្បធម៌ៈ អ្នកនិពន្ធបានឆ្លុះបញ្ចាំងនូវពុទ្ធសាសនា ដែលកំពុងតែមានឥទ្ធិពលនៅក្នុងសម័យលង្វែក។ ផ្សេងពីនោះ អ្នកនិពន្ធក៏បានលើកឡើងអំពីការបួសរៀនសម្រាប់ក្មេងប្រុស (តួអង្គទុំដែលត្រូវបានម្តាយយកទៅផ្ញើព្រះចៅអធិការឱ្យបានរៀនសូត្រតាំងពីតូចម្ល៉េះ) ការចូលម្លប់សម្រាប់ក្មេងស្រី (នាងទាវត្រូវបានរៀបចំឱ្យចូលម្លប់ដើម្បីថែរក្សាសម្បុរស្បែក និងរៀនវិជ្ជាមេផ្ទះ) និងពិធីអាពាហ៍ពិពាហ៍ (គ្រួសារអរជូនបានចាត់ឃ្នាយ ដែលចេះចាំស្ទាត់ខាងធម៌បរមត្ថដើម្បីចូលមកសាកសួរគ្រួសារខាងម្តាយទាវ មុននឹងឈានចូលទៅដល់ការរៀបការ)។

**គ.២. បំណិនសម្បទា**

កាលណាយើងនិយាយពីបំណិន គឺស្មើនឹងយើងធ្វើការនិយាយអំពីការអនុវត្ត។ វិជ្ជាសម្បទា ឬពុទ្ធិសម្បទា ដើរតួនាទីត្រឹមជាទ្រឹស្តី អាចឱ្យមនុស្សទទួលដឹងពីបញ្ហាផ្សេងៗដែលមាននៅក្នុងសង្គម។ ដោយឡែក បំណិនសម្បទា ជាការអប់រំដល់មនុស្សគ្រប់រូបឱ្យកើតមាននូវការគិតពិចារណា ចេះត្រិះរិះចេះវិភាគថ្លឹងថ្លែង និងពិនិត្យរកហេតុផលលើបញ្ហានានាបានច្បាស់លាស់ ស្របទៅតាមខ្លឹមសារដែលអ្នកនិពន្ធបានបង្ហាញក្នុងស្នាដៃអក្សរសិល្ប៍នីមួយៗ។ ការបណ្តុះនូវបំណិនសម្បទា ជាការឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងការសិក្សាអក្សរសិល្ប៍នៅសតវត្សទី២១ ត្បិតវាពុំត្រឹមតែឆ្លើយតបទៅនឹងតម្រូវការរបស់សង្គមនោះទេ តែវាក៏ផ្តល់នូវអត្ថប្រយោជន៍សម្រាប់បុគ្គលម្នាក់ៗផងដែរ។

នៅក្នុងអត្ថបទរឿង គូលីកំនែន ពូស្វាយមីងពត ក៏ដូចជាប្រជាជនខ្មែរមួយចំនួនទៀតនាំគ្នាយល់ឃើញថា ទុក្ខវេទនាទាំងឡាយដែលកើតមានចំពោះពួកគាត់ គឺបណ្តាលមកពីបញ្ហាកម្មនិងផលត្បិតថាជាតិមុនពួកគាត់ពុំបានសាងបុណ្យឱ្យបានក្រាស់ក្រែលទើបនាំឱ្យជាតិនេះ ពួកគាត់ត្រូវទទួលរងនូវទុក្ខវេទនា។ តែបើតាមទស្សនៈរបស់លឹមបែរដោយល់ថា ទុក្ខវេទនាទាំងឡាយរបស់ប្រជាជនគឺកើតចេញអំពីការជិះជាន់របស់ពួកអាណានិគម។ តាមរយៈឧទាហរណ៍នេះ យើងឃើញថាអ្នកនិពន្ធបានបណ្តុះស្មារតីមនុស្សឱ្យចេះវិភាគទៅលើបញ្ហានានាដែលកើតមាននៅក្នុងជីវភាពរស់នៅ ដោយផ្តោតលើតថភាពសង្គមជាគោល។ ក្នុងន័យនេះ ដើម្បីទទួលបាននូវសេរីភាព ឯករាជ្យ និងសេចក្តីសុខលុះត្រាតែប្រជាជនគ្រប់គ្នាមានស្មារតីស្រុះស្រួល ងើបឡើងរើបំរះចេញពីនឹមបរទេសនេះឱ្យបាន។

**គ.៣. ចរិយាសម្បទា**

ក្រៅពីការបណ្តុះនូវពុទ្ធិ និងបំណិន អក្សរសិល្ប៍នានាក៏បានចូលរួមនៅក្នុងការអប់រំមនុស្សឱ្យមានក្រមសីលធម៌ និងប្រកាន់ឥរិយាបថល្អចំពោះសង្គម សមជាពលរដ្ឋគម្រូ ជាធនធានមនុស្សពិតប្រាកដរបស់សង្គមជាតិផងដែរ។ តាមការលើកឡើងរបស់លោក គួយ សូគាន សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ ក្នុងបាឋកថាប្រចាំខែ រៀបចំឡើងដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការនិងសាសនា កាលពីឆ្នាំ២០១៨កន្លងទៅនេះ បានអះអាងថា "ការសិក្សាអក្សរសិល្ប៍ មានតួនាទីសំខាន់ណាស់សម្រាប់ឱ្យមនុស្សផ្លាស់ប្តូរនូវផ្នែកស្មារតី សីលធម៌ និងឧត្តមគតិជាតិ ប្រកបទៅដោយនិរន្តរភាព"។ ក្នុងន័យនេះ យើងអាចចាត់ទុកអក្សរសិល្ប៍ជាសាលាបណ្តុះនូវសីលធម៌ ត្បិតថាវាមិនត្រឹមតែ

ជាច្បាប់ ឬជាបន្ទាត់ដែលដឹកនាំ និងដាស់តឿនមនុស្សឱ្យមានក្រមសីលធម៌ល្អនោះទេ តែវាក៏បានចូលរួមកែប្រែអត្តចរិតមនុស្សដែលមិនល្អឱ្យមកជាល្អផងដែរ។ ទស្សនៈនេះដើរស្របនឹងទស្សនៈរបស់លោកឌីដឺរ៉ូ (ជនជាតិបារាំង) ដែលគាត់បានលើកឡើងថា "អក្សរសិល្ប៍សិល្បៈ មានសមត្ថភាពធ្វើឱ្យគុណធម៌ប្រែក្លាយជារបស់មួយគួរឱ្យស្រឡាញ់ និងបានធ្វើឱ្យគុណវិបត្តិក្លាយជារបស់មួយគួរឱ្យស្អប់ខ្ពើម"។

ជាក់ស្ដែងយើងសង្កេតឃើញថា ស្នាដៃអក្សរសិល្ប៍មួយចំនួនបានលើកឡើងនូវភាពវិជ្ជមានរបស់តួអង្គ ដើម្បីជាគម្រូអប់រំដល់ចរិយាសម្បត្តិរបស់មនុស្ស។ ដូចជានៅក្នុងរឿង កុលាបប៉ៃលិនជាតួយ៉ាង។ អ្នកនិពន្ធបានបង្ហាញដោយត្រង់នូវសុជីវធម៌ ស្មារតីតស៊ូ មនសិការការងារ និងភក្ដីភាពរបស់តួអង្គឯកចៅចិត្រ ដែលលក្ខណៈសម្បត្តិទាំងអស់នេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំចរិយាសម្បទារបស់មនុស្សឱ្យបានល្អ។ ដោយឡែក ស្នាដៃអក្សរសិល្ប៍ដទៃទៀតដូចជាស្នាដៃរឿង កាកី ជាដើម អ្នកនិពន្ធបែរជាលើកបង្ហាញនូវចំណុចអវិជ្ជមានដើម្បីជាការអប់រំចរិយាធម៌របស់មនុស្សទៅវិញ។ ក្នុងនោះយើងឃើញថាភាពសាវ៉ារបស់នាងកាកី គឺជាមេរៀនមួយដ៏សំខាន់ដែលអប់រំស្ត្រីខ្មែរទូទៅឱ្យមានកិរិយាមារយាទល្អ ចៀសវាងការប្រព្រឹត្តនូវអ្វីដែលខុសក្រមសីលធម៌របស់សង្គមនាំឱ្យមានការរិះគន់ និងពាក្យជំនៀលពីមនុស្សទូទៅ។

**ក.៤. តម្លៃសម្បទា**

អក្សរសិល្ប៍ មានទិសដៅស្វែងរកភាពសុខដុមក្នុងជីវភាពរស់នៅសម្រាប់មនុស្សផងក៏ដូចជាសង្គមទាំងមូលផងដែរ។ ក្នុងន័យនេះ អក្សរសិល្ប៍ ចាំបាច់ត្រូវតែបណ្ដុះស្មារតីសន្តិភាពរវាងមនុស្ស និងមនុស្ស ធ្វើយ៉ាងណាពង្រឹងឱ្យបាននូវសាមគ្គីភាព ភាពស្រុះស្រួល និងការរួបរួមកម្លាំងគ្នាក្នុងសង្គម[6]។ តាមវិធីនេះ អក្សរសិល្ប៍អាចរក្សាបាននូវគម្លាតវណ្ណៈ ការរើសអើង និងការពារមិនឱ្យមានការកេងប្រវ័ញ្ច ការជិះជាន់ គម្រាមកំហែងក្នុងនាមជាជាតិសាសន៍តែមួយ។

យើងអាចមើលឃើញនូវតម្លៃសម្បទានេះតាមរយៈស្នាដៃអក្សរសិល្ប៍រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់។ ក្នុងនោះយើងសង្កេតឃើញថា ការផ្សះផ្សាវណ្ណៈរបស់អ្នកនិពន្ធបានធ្វើឱ្យសម និងលោករដ្ឋមន្ត្រីវ៉ៃក្មេងមានឱកាសបានជួបប្រាស្រ័យទាក់ទងគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមក។ នេះជាការកសាងនូវសន្តិភាពរវាងមនុស្សនិងមនុស្សក្នុងសង្គម លុបបំបាត់បាននូវគម្លាតវណ្ណៈ ធ្វើឱ្យជីវភាពរស់នៅរបស់មនុស្សកាន់តែមានភាពរីកចម្រើន។ តាមរយៈខ្លឹមសារនេះ ជនក្រីក្រទាំងឡាយមិនត្រូវផ្ដេកផ្ដួលតែលើព្រេងកម្មវាសនានោះទេ រីឯអ្នកមានទាំងឡាយក៏ពុំគួរណាប្រកាន់ខ្លួន ឬប្រកបដោយភាពអំនួតលើមុខងារ តួនាទីខ្លាំងពេកនោះដែរ។ ក្នុងន័យនេះ ជនក្រីក្រត្រូវតែមានស្មារតីតស៊ូ ស្គាល់តម្លៃការងារ ចំណែកឯអ្នកមានត្រូវចេះបន្ទាបខ្លួន ទើបអាចរស់នៅជាមួយគ្នាប្រកបដោយភាពស្រុះស្រួល សាមគ្គី និងរីកចម្រើន។

---

[6] គីម សួរ *ទ្រឹស្ដីអក្សរសិល្ប៍* ២០១២

## ខ. តួនាទីនៅក្នុងការផ្សព្វផ្សាយវប្បធម៌

ក្រៅពីការផ្ដល់នូវពុទ្ធិ ក៏ដូចជាការអប់រំដល់មនុស្ស ស្នាដៃអក្សរសិល្ប៍នីមួយៗក៏មានតួនាទីនៅក្នុងការផ្សព្វផ្សាយវប្បធម៌ជាតិផងដែរ។ តាមរយៈខ្លឹមសារនៃអត្ថបទអក្សរសិល្ប៍នីមួយៗ គេអាចប្រទះឃើញនូវជំនឿ សាសនា ផ្នត់គំនិត ប្រពៃណីទំនៀមទម្លាប់ ។ល។ ដែលជាចំណែកនៃវប្បធម៌ជាតិ យ៉ាងសម្បូរបែប។ ការឆ្លុះបញ្ចាំងនូវវប្បធម៌ជាតិទាំងនេះ ពុំមែនត្រឹមតែអាចឱ្យអ្នកសិក្សាជំនាន់ក្រោយ បានសិក្សាស្វែងយល់អំពីវប្បធម៌នោះទេ តែវាក៏បានចូលរួមផ្សព្វផ្សាយឱ្យបរទេសទូទៅបានសិក្សាស្វែងយល់ និងស្គាល់ច្បាស់ពីទំនៀមដ៏ល្អផូរផង់របស់ខ្មែរផងដែរ។

ជាក់ស្ដែង តាមរយៈស្នាដៃអក្សរសិល្ប៍រឿងផ្កាស្រពោន[7] យើងអាចស្គាល់អំពីវប្បធម៌ខ្មែរជាច្រើនមានដូចជា៖

- ជំនឿ
  - ជឿលើម្ដាយឪពុកៈ ប្រជាជនខ្មែរនិយមគោរព និងឱ្យតម្លៃលើឪពុកម្ដាយ ឬអ្នកមានគុណណាស់។ តួយ៉ាងនាងវិធាវីជាក្មេងស្ដាប់បង្គាប់ម្ដាយពន់ប្រមាណ បើទោះបីម្ដាយខុសម្ដេចម្ដាក៏មិនហ៊ានតបត ឬប្រើសម្ដីអសុរោះឡើយ ដូចមានឃ្លាដែលនាងបាននិយាយថា"ស្ត្រីខ្មែរមិនមានអំណាចរើសប្ដីខ្លួនឯងទេ បើឪពុកម្ដាយទុកដាក់ល្អអាក្រក់ដូចម្ដេច ក៏ត្រូវតែទទួលយកជានិច្ច" (ទំព័រទី៦៧)។
  - ជឿលើការបន់ស្រន់ៈ វេលាដែលមនុស្សកើតមាននៅទុក្ខវិបត្តិដែលដោះស្រាយមិនបាន ការបន់ស្រន់គឺជាវិធីមួយបែបដែលអាចបន្ថយភាពតានតឹង ក៏ជាអារម្មណ៍ភ័យខ្លាចនានារបស់ប្រជាជនខ្មែរ។ ការបន់ស្រន់នេះ វាជាជំនួយដែលអាចជួយឱ្យមនុស្សកើតមាននូវសេចក្ដីស្ងប់សុខខាងផ្លូវចិត្ត ដូចកាលដែលនាងវិធាវី អុជធូបបន់សុំឱ្យប៊ុនធឿនប្រឡងជាប់ (ទំព័រទី១៥) និងកាលដែលនាងអុជធូបផ្សងនៅប្រាសាទបាយ័នជាដើម "...ខ្ញុំព្រះករុណាបានកាន់សីលប្រាំខ្ជាប់មិនរសាយ បានធ្វើបុណ្យបំពេញទានតាមកំឡាំងទ្រព្យនៃយុវជន ហើយបានស្គាល់ព្រះធម៌ទាំងពួងផង។ ហេតុនេះសូមព្រះអង្គសន្ដោសជួយខ្ញុំ ព្រះករុណាឱ្យបានរួចពីក្រញាំចៅណៃស៊ិតកំណាចចេញ ហើយឱ្យខ្ញុំព្រះករុណាជួបតែបងប៊ុនធឿនដែលជាគូព្រេងកំសត់រៀងទៅ" (ទំព័រទី៦៤)។
  - ហោរាសាស្ត្រ និងការចាក់គម្ពីរៈ ខ្មែរមានជំនឿលើការទស្សន៍ទាយ មើលថ្ងៃខែឆ្នាំកូនប្រុសស្រី មុននឹងរៀបចំឱ្យមាននូវពិធីរៀបអាពាហ៍ពិពាហ៍[8] ។ តួយ៉ាង បន្ទាប់អំពីយាយចាន់ប្រាប់ពីថ្ងៃខែឆ្នាំរបស់ណៃស៊ិត យាយនួនបានទៅរកគ្រូអានវត្តពោធិ៍ដើម្បីទស្សន៍ទាយជតារាសីរើសគូស្រករឱ្យកូនគាត់។ នៅទំព័រទី៣៦ "...ខ្ញុំព្រះករុណាយកម្លូស្លាបារីនេះមកប្រគេនលោកគ្រូម្ចាស់ ហើយសុំនិមន្តលោកគ្រូម្ចាស់មើលដួងជតាកូនខ្ញុំព្រះករុណា ព្រោះខ្ញុំព្រះ

[7] សូមមើលរឿង *ផ្កាស្រពោន* របស់លោក នូ ហាច ១៩៤៨

[8] ទេស ហាវ *អរិយធម៌ខ្មែរ* ២០១២

ករុណាចង់ឱ្យវាមានគូស្រករ″។ បន្តពីនេះ យាយនួនបានសុំព្រះគ្រូចាក់គម្ពីរបន្ថែម ដើម្បីឱ្យកាន់តែច្បាស់។ លោកគ្រូអានទាញគម្ពីរសាស្ត្រាដាក់លើតោកឈើមួយ រួចលូកយកទៀនក្រមួនឃ្មុំអុជបិទនឹងក្របតោក។ យាយនួនលើកហត្ថសំពះបីដង លើកគម្ពីរដាក់លើក្បាលរួចចាក់ផ្សង។ គ្រូអានទាញគម្ពីរដែលយាយនួនបានចាក់ ឃើញត្រង់ព្រះមហោសថជួបនាងអមរា រួចមានសង្ឃដីកាថា ល្អពេកក្កាត់ ទុកជាគាប់ប្រសើរក្រៃលែង។

- ការស្រោចទឹកៈ ទំនៀមនៃការស្រោចទឹក ខ្មែរនិយមហៅជាការលើករាសី ឬរដោះនូវគ្រោះឧបទ្រពចង្រៃផ្សេងៗ។ អាស្រ័យដោយហេតុនេះហើយបានជានាងថូប្រញាប់ប្រញាល់ឱ្យគេយកឡានទៅនិមន្តលោកវត្តភ្នំសំពៅមកស្រោចទឹកឱ្យវិធារី។ ‶...ថាំងមួយមានទឹកពេញមានផ្កាម្លិះក្រពុំអណ្ដែតសក្បុស។ លោកយកធូបបីសរសៃមកផ្គុំគ្នានឹងជុំក្រមួន ហើយយកទៅបិទជាប់នឹងមាត់ធុងទឹក...ព្រះសង្ឃក៏លើកទឹកនោះ ទៅស្រោចលើខ្លួននាងដែលកំពុងគ្រុនយ៉ាងក្តៅ...″ (ទំព័រទី៧០)។
- បួលបញ្ជាន់អារក្ខៈ ការបួល និងការបញ្ជាន់អារក្ខនេះ ធ្វើឡើងតាមគំនិតដែលថាជម្ងឺអ្វីមួយបានកើតលើបុគ្គលណាម្នាក់ភ្លាមៗដោយមិនដឹងមុខ។ ខ្មែរនិយមហៅថាខុសមេបា ជាន់ពៃខុសមាត់ខុសក ឬត្រូវព្រលឹងខ្មោចណាមួយប្រកាន់ខឹងជាដើម។ ហេតុនេះគេត្រូវរកគ្រូបួល និងបញ្ចូលរូបដើម្បីលៀងខ្មោច ឬសុំការខមាទោស[9] ។ តាមរយៈសាច់រឿង នាងថូនឹកពិភាល់ក្រែងមានទាស់ខុសនឹងខ្មោចបិសាចណាទើបបណ្ដាលឱ្យវិធារីឈឺ។ នាងថូបានទៅអញ្ជើញម៉ែអេងដែលពូកែខាងបួល គាត់យកអំបោះចងប្រណាកបន្ទំលើក្បាល ហៅឈ្មោះព្រលឹងអ្នកតា អារក្ស ខ្មោចព្រាយបិសាចនានា រួចបញ្ចប់ត្រឹមនាងកន្ទោងខៀវ (ទំព័រទី៧៣)។
- ជំនឿលើអ្នកតាៈ នៅតាមព្រៃភ្នំ ប្រជាជនខ្មែរនិយមជឿថាតែងតែមានព្រលឹងអ្នកតានៅចាំថែរក្សាការពារ[10] ។ ហេតុនេះវេលាដែលដើរព្រៃ ថ្មើរទាំងឡាយត្រូវតែមមាត់ក កុំនិយាយផ្ដេសផ្ដាស និងត្រូវរៀបចំសំណែនកុំឱ្យខាន។ ដោយឡែក ក្នុងដំណើររកត្រីក្នុងព្រៃរនាមរបស់ប៊ុនធឿន និងអ្នកភូមិដទៃទៀត យើងឃើញមានការបង្ហាញវត្តមានអ្នកតាដង្កោតាធិល ដូចមានឃ្លាបញ្ជាក់ថា ‶...នៅក្នុងខ្ទមមានបដិមាមួយធ្វើពីថ្មខ្មៅប្រផេះ។ រូបនោះមានបបូរមាត់ធ្លាក់សំយេះ ហើយមានផ្ទាំងជាតីរុំព័ទ្ធជាក្រមា។ រូបចំលាក់នេះជារូបអ្នកតាដង្កោតាធិលដែលមានរិទ្ធានុភាពខ្លាំងពូកែណាស់។ អ្នកដំណើររទេះ កាលបើបានដល់ទីទួលនេះហើយតោងខ្ចីឃ្នាតកាច់មែកឈើ ច្រូចស្រា សែនបាយទឹក ចំណីចំណុកដើម្បីសូមលាភ សូមជ័យពីលោកអ្នកតា″ (ទំព័រទី៧៩)។

---

[9] ត្រឹង ងា *អរិយធម៌ខ្មែរ* ១៩៧៥

[10] ឆយ យីហ៊ាង និងយ៉ង់ ធី *អត្តសញ្ញាណប្រទេសកម្ពុជា ២០០០*

- ការដើរព្រៃៈ ការដើរព្រៃ ប្រជាជនខ្មែរនិយមប្រកាន់ត្រណម និងការអនុវត្តច្រើនប្រការណាស់។ ត្បិតនៅក្នុងព្រៃមានទាំងសត្វសាហាវ និងអមនុស្សផ្សេងៗ ដែលតម្រូវឱ្យយើងគោរពឱ្យបានខ្ជាប់ខ្ជួន។ បើពុំនោះសោត យើងជឿថានឹងអាចកើតមាននូវគ្រោះថ្នាក់នានាជាយថាហេតុនៅក្នុងការដើរព្រៃ។ គេនិយមរកមនុស្សម្នាក់ដែលស្គាល់ព្រៃច្បាស់ និងចេះមន្តអាគមតិចតួចឱ្យនាំមុខ ហៅថាជង្ហ្វា បើគាត់និយាយបង្គាប់បែបណាមួយ តោងស្ដាប់គាត់ហើយធ្វើតាមគាត់ជានិច្ច។ ក្នុងដំណើរទៅកាន់ព្រៃរនាម "...បុរសនេះឈ្មោះប្រាក់ជាអ្នកខ្លាំងពូកែ ចេះមន្តអាគមធ្វើគ្រូហ្មបាន។ គាត់ស្គាល់ផ្លូវរនាមខ្វេចគ្មានសល់។ ពួកក្រុមដែលដើរព្រៃជាមួយគាត់ មិនដែលស្គាល់ថាដូចម្ដេចហៅថាវង្វេងផ្លូវសោះឡើយ...ហេតុនេះហើយបានជាពួកដើរព្រៃតែងតាំងគាត់ជាជង្ហ្វា គឺជានាយក" (ទំព័រទី៨១)។
- ការសិក្សាអប់រំៈ ការសិក្សាមាននៅសាលារដ្ឋ សាលាបារាំង(សាលាកិលេស) ឬតាមទីវត្តអារាមនានាផងដែរ។ តួយ៉ាងតួអង្គប៊ុនធឿនត្រូវចាកចេញពីបាត់ដំបង មករៀននៅរាជធានីភ្នំពេញដើម្បីត្រៀមប្រឡងយកសញ្ញាបត្រឌីប្លូម។ ដោយឡែក នាងវិជាវីធ្លាប់បានទៅរៀននៅវត្តពោធិវាល ពេលទំនេរនាងរៀនភាសាសៀម និងវិជ្ជាដេរប៉ាក់ រហូតអាចមើលរឿងសៀមបាន ហើយបង្អួចផ្ទះ ស្រោមខ្នើយ មានក្បាច់កើតចេញពីការអញ្ចុលរបស់នាងទាំងអស់ (ទំព័រទី៩)។
- សិល្បៈ
  - ចម្រៀងៈ សិស្សវិទ្យាល័យ(សាលាបារាំង) ភាគច្រើននិយមទទួលយកនូវវប្បធម៌បរទេស តួយ៉ាងក្នុងដំណើរត្រឡប់មកផ្ទះវិញ សិស្សមួយចំនួនច្រៀងចម្រៀងទំនុកបារាំង។
  - ល្បែងប្រជាប្រិយៈ ការសម្ដែងសិល្បៈបានបង្ហាញនៅតាមទីសាធារណៈ ក្នុងនោះប្រជាជនខ្មែរអាចចូលរួមទស្សនា កម្សាន្តសប្បាយយ៉ាងរីករាយ។ នៅថ្ងៃ១៤ ស៊ូយ៉េត (ថ្ងៃបុណ្យជាតិបារាំង)ប្រជាជនខ្មែរនាំគ្នាប្រជ្រៀត មើលល្បែងផ្សេងៗ ដូចជាលេងចងជើងក្នុងបាវរត់ប្រណាំង និងមានឡើងសសរលោបខ្លាញ់ជាដើម។
  - អក្សរសាស្ត្រអក្សរសិល្ប៍ៈ អក្សរសាស្ត្រអក្សរសិល្ប៍ខ្មែរសម័យអាណានិគមបារាំងទទួលឥទ្ធិពលពីចរន្តពីរ តាមការវិវត្តរបស់ប្រវត្តិសាស្ត្រ ពោលគឺអក្សរសិល្ប៍ប្រពៃណី និងអក្សរសិល្ប៍ទំនើប ។ សម្រាប់ប្រជាជនខ្មែរ ជាពិសេសបុគ្គលដែលមានវ័យចំណាស់ ចូលចិត្តនិយមរឿងរ៉ាវដែលជាប់ពាក់ព័ន្ធនឹងពុទ្ធសាសនា ដូចជាពពួកសាស្ត្រាល្បែងអ្វីនេះជាដើម។ ដូចជានៅទំព័រទី១០ "យាយនួនគាត់មានកង្វល់ក្នុងចិត្ត ហើយគាត់បានបបួលកូនគាត់ឱ្យមើលក្រាំងព្រះលក្ខិណវង្សកែអផ្សុក... លុះដល់គេបណ្ដើរឱ្យនាងព្រាហ្មណ៍កេសរស្រែកអាក្រោសតាមផ្សារ យាយផៃគាត់ខឹងខ្លាំងណាស់ ទប់មិនបានក៏ស្ទុះក្រោកឈរឡើងហើយស្រែកថាៈ អញថាហើយ!..ថាកុំឱ្យមកតាម..ប្រុសឥឡូវតែយ៉ាងនេះឯងបានថ្មីចោលចាស់ឥតពិគ្រោះពិចារណាទេ!"។ ផ្សេងពីនេះ យើងក៏ឃើញមានលំហូរនៃវប្បធម៌អក្សរសិល្ប៍

បរទេសផងដែរ តួយ៉ាងតួអង្គប៊ុនធឿនដែលបានទៅរៀននៅសាលាបារាំងឯភ្នំពេញ អាចមានសមត្ថភាពអានរឿង ប៉ូល វីហ្សីនី ដែលជាអក្សរសិល្ប៍បារាំងចែកវិជាវីស្តាប់បាន។

- ➢ ក្លែងអារក្ខៈ យើងឃើញមានការប្រគំវង់ភ្លេងអារក្ខ ក្នុងពិធីបញ្ចូលខ្មោច អារក្ស បិសាច អ្នកតា។ ក្នុងនោះស្គរ គឺជាឧបករណ៍ភ្លេងសំខាន់ ដូចអ្វីដែលនូហាចបានរៀបរាប់ថា "...នៅពេលល្ងាចនោះ គេឃើញមនុស្សប្រមឹកបួនប្រាំនាក់ កាន់ស្គរដាសដោយស្បែកពស់ថ្លាន់ និងក្រពើចូលមកលេងភ្លេងញ៉ៅៗហើយច្រៀងបន្ទរផង..." (ទំព័រទី៧៣) ។

- ទំនៀមប្រពៃណី
  - ➢ ការទុកដាក់កូនចៅៈ សិទ្ធិនៅក្នុងការជ្រើសរើសគូស្រករគឺសម្រេចលើម្ដាយឪពុកជាអ្នករៀបចំ ជាក់ស្ដែងម្ដាយឪពុករបស់វិជាវី និងប៊ុនធឿន បានរៀបចំទុកដាក់អ្នកទាំងពីរជាគូស្រករនឹងតាំងពីតូចក្រូចឆ្មារមកម្ល៉េះ ក្នុងនោះពួកគាត់បានសម្រេចថា "ឪពុកឯង និងចិកប៊ុនថនឪពុកប៊ុនធឿននេះជាក្លើម្រាក់នឹងគ្នា... បាននិយាយផ្ដែផ្ដាំទុកដាក់ឯងនេះជាគូនឹងប៊ុនធឿន ដល់កាលណាប៊ុនធឿនជាប់ឌីប្លូម"(ទំព័រទី១២)។
  - ➢ ការចែចូវៈ តាមទំនៀមខ្មែរ មុននឹងឈានចូលទៅដល់ការស្ដីដណ្ដឹង ឬពិធីអាពាហ៍ពិពាហ៍មុនដំបូងបង្អស់ ឪពុកម្ដាយខាងប្រុសត្រូវចាត់ស្រីម្នាក់ ដែលគេស្គាល់ទុកចិត្តថាមិនអកព្វ ហើយធ្លាប់ស្និទ្ធស្នាលនឹង គ្រួសារខាងស្រី (ហៅថាអ្នកឃ្នាយឬមេអណ្ដើក) ឱ្យចូលចែចូវ។ ពិធីនេះ គេធ្វើឡើងគម្រប់បីលើក ពោលគឺទម្រាំតែខាងស្រីអនុញ្ញាតបើកផ្លូវឱ្យដើរជណ្ដើរឱ្យឡើង ទើបគេចាប់គិតគូរកិច្ចជាបន្តទៀត។ ក្នុងដំណើររឿង យាយចាន់ដែលជាចាស់ទុំតំណាងឱ្យគ្រួសារនាងថូ បានចូលមកសុំសួរនាងវិជាវីពីយាយនួន។ យាយនួនសួររកថ្ងៃខែណែស៊ត ហើយកាន់ម្លូ បារីមួយស៊ងដាក់លើជើងពាន និងទៀនមួយគូឱ្យគ្រូអានដែលពូកែខាងហោរាសាស្ត្រ និងមន្តអាគមស្ដោះព្រួស មើលជតារាសីរើសគូស្រករ។
  - ➢ បុណ្យសពៈ នៅបាត់ដំបង វេលាដែលមានមនុស្សស្លាប់ គេនិយមតម្កល់សពរយៈពេល៣ទៅ៥ឬ៧ថ្ងៃតាមធនធាន។ ក្នុងនោះសាច់ញាតិបុគ្គលដែលស្លាប់មានស្លៀកពាក់ស កោរសក់កាន់ទុក្ខ ដូចនៅក្នុងទំព័រ ទី៨៩ អ្នកនិពន្ធបានរៀបរាប់ថា "កំលោះនេះភ្ញាក់ខ្លួន ហើយងាកមើលទៅស្គាល់ជាម៉ែផៃ ដែលមានសក់កោរថ្មីៗ ហើយស្លៀកពាក់សតាមធម្មតាជាអ្នកកាន់ទុក្ខ"។
  - ➢ ទំនៀមបរទេសៈ ខ្មែរចូលរួមប្រារព្ធទិវាជាតិបារាំង ១៤ កក្កដា ដើម្បីរំលឹកដល់ថ្ងៃដែលបារាំងទម្លាយជញ្ជាំងគុក Bastille កាលពីឆ្នាំ១៧៨៩ វាជាចំណុចចាប់ផ្ដើមនៃបដិវត្តន៍បារាំងក្នុងការផ្លាស់ប្ដូរពីរបបរាជានិយម ទៅជារបបសាធារណរដ្ឋបារាំង។ ជាក់ស្ដែងនៅក្នុងអត្ថបទរឿង "នៅល្ងាចថ្ងៃ ១៣កក្កដា ចិកប៊ុនថននិយាយទៅ កាន់បុត្រគាត់ថាៈ ថ្ងៃស្អែកនេះជាថ្ងៃបុណ្យជាតិរបស់បារាំង។ បើឯងចង់ទៅមើលបុណ្យនោះក៏ទៅចុះ" (ទំព័រ២៣)។

- សាសនា និងការគោរពបូជា៖ ប្រជាជនខ្មែរគោរពពុទ្ធសាសនា រមែងរៀបចំចង្ហាន់ទៅប្រគេនលោកឯវត្ត ដូចនៅត្រង់ទំព័រទី ២៦ "ជួនជាថ្ងៃនេះជាថ្ងៃពេញបូណ៌មី។ យាយនួនគាត់ទៅកាន់ឧបោសថឯវត្តពោធិ៍។ នាងវិធាវីកាល បើម្ហូបរៀបចំដាក់ចានស្រាក់ ឱ្យម៉ែផៃគាត់លើកទៅជូនម្ដាយនាងរួចស្រេចហើយ..."។ ម៉្យាងវិញទៀត នៅពេលដែលពើបប្រទះនឹងបញ្ហាទុក្ខសោកនានា មនុស្សតែងតែយកពុទ្ធសាសនាជាពំនាក់អាស្រ័យ ជាទីពឹងផ្លូវចិត្ត តួយ៉ាងក្នុងដំណើរទៅលេងសៀមរាប វិធាវីឆ្លៀតចូលបន់ស្រន់ចំពោះមុខពុទ្ធបដិមានៅចំហៀងប្រាសាទបាយ័ន ប្រាថ្នាសុំឱ្យបានរួចផុតពីដៃណៃស៊ត (ទំព័រ៦៤)។

### គ. តួនាទីនៅក្នុងការជម្រុញការអភិវឌ្ឍសង្គម

តាមទស្សនៈរបស់លោកគ័រ គី (ជនជាតិរុស្ស៊ី)ទាក់ទងទៅនឹងទំនាក់ទំនងអក្សរសិល្ប៍ ជាមួយនឹងសង្គមញាណជវៃ លោកបានពោលថា "អក្សរសិល្ប៍គឺជាការប្រយុទ្ធដើម្បីប្រឆាំង" មានន័យថារាល់ស្នាដៃអក្សរសិល្ប៍នីមួយៗត្រូវបំពេញ និងកែលម្អនូវអ្វីដែលជាភាពខ្វះខាតនៅក្នុងសង្គម ធ្វើយ៉ាងណាជម្រុញសង្គមឱ្យទទួលបាននូវភាពរីកចម្រើន។ ក្នុងនោះ អ្នកនិពន្ធទាំងឡាយត្រូវមានទំនួលខុសត្រូវចំពោះមុខសង្គម ដូចអ្វីដែលលោក ស៊ី លឺរ (Schiller) ទស្សនវិទូអាល្លឺម៉ង់បាននិយាយថា "សិល្បករទាំងឡាយត្រូវទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួននៅចំពោះមុខសង្គម បើមើលឃើញសង្គមបែបណាត្រូវហ៊ាននិយាយបែបនោះ"។ ពេលខ្លះការលើកឡើងពីភាពអសកម្មរបស់សង្គម មិនមែនមានន័យថា អ្នកនិពន្ធកំពុងតែបន្ទុះបង្អាប់ ឬជាន់ពន្លិចសង្គមរស់នៅរបស់ខ្លួននោះទេ តែវាជាការគាស់កកាយឱ្យឃើញនូវបញ្ហានានាដែលមនុស្សកំពុងតែជួបប្រទះ ដោយផ្ដល់នូវការដោះស្រាយមួយដ៏ល្អសម្រាប់សង្គមរស់នៅជាក់ស្ដែង។

#### គ.១. ការលើកឡើងនូវបញ្ហាសង្គម

ការវិវត្តឥតឈប់ឈរនៃសង្គមរស់នៅ ធ្វើឱ្យមនុស្សជួបប្រទះនូវបញ្ហាផ្សេងៗគ្នា។ ពីមួយរយៈកាលទៅមួយរយៈកាល អ្នកនិពន្ធបានលើកបង្ហាញនូវបញ្ហាសង្គមជាច្រើនតាមរយៈស្នាដៃអក្សរសិល្ប៍របស់ខ្លួន។ ក្នុងនោះ យើងសង្កេតឃើញមានបញ្ហាសំខាន់ៗដូចជា៖

##### គ.១.១. បញ្ហាវណ្ណៈ

បញ្ហាវណ្ណៈជាបញ្ហាមួយដ៏រសើប និងស្រួចស្រាវបំផុតក្នុងវិស័យអក្សរសិល្ប៍ខ្មែរ។ មានខ្សែរឿងជាច្រើន ដែលអ្នកនិពន្ធបានឆ្លុះបញ្ចាំងនូវបញ្ហាមួយនេះ។ ជាក់ស្ដែង បញ្ហាវណ្ណៈនៅក្នុងរឿងទុំទាវដែលយើងឃើញថាបើទោះបីជានៅចុងបញ្ចប់ ទុំបានអភិវឌ្ឍខ្លួនរហូតបានទទួលងារជាម៉ឺនឯកបម្រើការក្នុងរាជវាំងក៏ដោយក៏ម្ដាយទាវនៅតែមិនពេញចិត្តនឹងលើកទាវឱ្យទុំដែរ។ ដោយឡែកបញ្ហាវណ្ណៈនៅក្នុងរឿងកុលាបប៉ៃលិន ក៏ដូចជារឿងមាលាដួងចិត្ត សុទ្ធតែបានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពប្រឈមជាច្រើនដែលបុគ្គលដែលស្ថិតនៅក្នុងវណ្ណៈតូចទាបត្រូវប្រឈមមុខ និងស្វែងរកដំណោះស្រាយដើម្បីអនាគតរបស់ខ្លួន។

### គ.១.២. បញ្ហាសិទ្ធសេរីភាព និងការគ្រប់គ្រង

សិទ្ធសេរីភាព និងការគ្រប់គ្រង ជាបញ្ហារបស់ពិភពលោកទាំងមូល។ មិនមែនមានតែនៅក្នុងស្នាដៃអក្សរសិល្ប៍របស់ខ្មែរនោះទេ សូម្បីស្នាដៃអក្សរសិល្ប៍បរទេសក៏បានឆ្លុះបញ្ចាំងឱ្យឃើញនូវបញ្ហានេះផងដែរ តួយ៉ាងដូចមានរឿងរ៉ូមេអូ ជូលីយែតជាដើម។ បើនិយាយអំពីបរិបទអក្សរសិល្ប៍ខ្មែរ បញ្ហាសិទ្ធសេរីភាព និងការគ្រប់គ្រងនេះផុសឡើងខ្លាំងនៅក្នុងសម័យអាណានិគម (១៨៦៣ដល់១៩៥៣) ដែលក្នុងនោះអ្នកនិពន្ធមួយចំនួនបានបំផុសស្មារតីប្រជាជនឱ្យងើបឡើងទាមទារសិទ្ធសេរីភាព ប្រឆាំងនឹងការគ្រប់គ្រងបែបផ្ដាច់ការរបស់ពួកអាណាព្យាបាលនានា។ តាមរយៈអត្ថបទរឿង ភូមិតិរច្ឆាន រឿងគូលីកំនែន និងរឿងគ្រូបង្រៀនស្រុកស្រែ សុទ្ធសឹងតែជាស្នាដៃឆ្លុះបញ្ចាំងនូវភាពអសកម្មក្រោមការដឹកនាំរបស់ក្រុមអាណាព្យាបាល ដែលជាប្រភពបង្កជាទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនខ្មែរ។

### គ.១.៣. បញ្ហាជំនឿ និងផ្នត់គំនិតចាស់គំរិល

ជំនឿ និងផ្នត់គំនិតរបស់មនុស្សជារឿងមួយដែលយើងពិបាកនៅក្នុងការកែប្រែណាស់។ ទោះបីជាពេលខ្លះ វិទ្យាសាស្ត្រមានភាពរីកចម្រើនយ៉ាងណាក៏ដោយ ក៏ប្រជាជនមួយចំនួននៅតែមិនទាន់បោះបង់ចោលនូវជំនឿ និងផ្នត់គំនិតដែលបន្តមកពីបរមបុរាណនោះដែរ។ ជាក់ស្ដែង ទស្សនៈ "នំមិនធំជាងនាឡិ" ដូចយើងបានឃើញមាននៅក្នុងអត្ថបទរឿងទុំទាវ ដែលក្នុងនោះម្ដាយឪពុកភាគច្រើន នាសម័យលង្វែកប្រកាន់នូវគំនិតផ្ដាច់ការនៅក្នុងការរៀបចំទុកដាក់គូស្រករឱ្យកូន ដោយពុំបានផ្ដល់សិទ្ធសេរីភាពដល់ពួកគេនៅក្នុងការសម្រេចចិត្តដោយផ្ទាល់នោះទេ។ ទស្សនៈនេះយើងឃើញមានកើតឡើងជាបន្តបន្ទាប់ រហូតមកដល់សម័យអាណានិគមដូចមានបង្ហាញតាមរយៈតួអង្គយាយនួននៅក្នុងរឿងផ្កាស្រពោនជាដើម។ ទស្សនៈយាយនួន និងម្ដាយទាវពុំមានភាពខុសគ្នាត្រង់ថា ម្នាក់ៗសុទ្ធតែឱ្យតម្លៃលើទ្រព្យសម្បត្តិ ហើយប្រើប្រាស់នូវសិទ្ធជាឪពុកម្ដាយដើម្បីបង្ខិតបង្ខំកូន។ ទស្សនៈនេះក៏បានបន្តឥទ្ធិពលរបស់ខ្លួនមកដល់ពេលបច្ចុប្បន្នផងដែរ ដែលក្នុងនោះយើងសង្កេតឃើញថាឪពុកម្ដាយមួយចំនួននៅតែប្រើប្រាស់សិទ្ធរបស់ខ្លួននៅក្នុងការអារកាត់រឿងជីវិតរស់នៅរបស់កូនចៅនៅឡើយ។

## គ.២. ការសាកល្បងផ្ដល់នូវដំណោះស្រាយ

ដូចអ្វីដែលយើងបានបញ្ជាក់ពីខាងដើមស្រាប់ ក្រៅពីការលើកបង្ហាញនូវបញ្ហាសង្គមនានា អ្នកនិពន្ធទាំងឡាយក៏បានឆ្លុះបញ្ចាំងឱ្យឃើញនូវដំណោះស្រាយតាមមនោគតិរៀងខ្លួនៗ។ ទស្សនៈទានទាំងអស់នោះ ចាត់ទុកជាបទពិសោធន៍ដ៏មានតម្លៃដែលអាចឱ្យអ្នកអាន អ្នកសិក្សាទូទៅរក្សាទុកជាគតិជាច្បាប់អប់រំ ក៏ដូចជាខ្លឹមសារដើម្បីវិភាគបន្តលើបញ្ហាសង្គមនានា។

### គ.២.១.បញ្ហាវណ្ណៈ

នៅក្នុងស្នាដៃរឿងទុំទាវ ភិក្ខុសោមបានបង្ហាញនូវស្មារតីតស៊ូព្យាយាមយ៉ាងស្វិតស្វាញរបស់តួអង្គទុំនិងទាវ ដើម្បីជំនះនូវបញ្ហាវណ្ណៈដែលរារាំងដល់ស្នេហារបស់ពួកគេទាំងពីរ។ តែយ៉ាងណា នៅចុងបញ្ចប់នៃរឿងតួអង្គទាំងពីរនៅតែពុំអាចដោះស្រាយបញ្ហានោះបាន បើទោះបីជាមានការអន្តរាគមន៍ពីសំណាក់ព្រះរាជាក៏ដោយ។ ដោយឡែកបើយើងសង្កេតមកមើលការដោះស្រាយរបស់អ្នកនិពន្ធញ៉ុកថែមនៅក្នុងស្នាដៃរឿង កុលាបប៉ៃលិនឯណោះវិញ។ តាមរយៈដំណើររឿង យើងដឹងថាចៅចិត្រស្ថិតក្នុង

វណ្ណៈក្រីក្រ ខុសពីឃុននារីដែលស្ថិតនៅក្នុងវណ្ណៈអភិជន។ តែយ៉ាងណា អ្នកនិពន្ធបានព្យាយាមដោះស្រាយនូវបញ្ហាវណ្ណៈទាំងអស់នេះ ដោយឱ្យតួអង្គចៅចិត្រមានការតស៊ូ ព្យាយាមក្នុងកិច្ចការងារ និងត្រូវប្រកាន់ភ្ជាប់នូវភាពស្មោះត្រង់ ស្របពេលដែលលោកហ្លួងរតនសម្បត្តិក៏ដូចជាឃុននារីជាកូន ត្រូវចេះបន្ទាបខ្លួន ផ្តល់ឱកាសដល់អ្នកដទៃជាពិសេសអ្នកដែលមានវណ្ណៈតូចទាបជាងខ្លួន។ តាមរយៈដំណោះស្រាយមួយនេះ បញ្ហាវណ្ណៈត្រូវបានដោះស្រាយទាំងស្រុង ហើយអ្នកមាននិងអ្នកក្រក៏អាចរួមរស់ជាមួយគ្នាពោរពេញទៅដោយភាតរភាព និងសេចក្តីសុខជាកិយ្យោភាព។

### គ.២.២. បញ្ហាសិទ្ធសេរីភាព និងការគ្រប់គ្រង

ដោយសារការរស់នៅក្រោមការដឹកនាំរបស់ពួកអាណានិគម បង្កតែនូវភាពឈឺចាប់ និងទុក្ខវេទនាឥតឈប់ឈរ អ្នកនិពន្ធក៏បានចូលរួមនៅក្នុងប្រើប្រាស់អត្ថបទសំណេររបស់ខ្លួនដើម្បីជាអាវុធប្រយុទ្ធប្រឆាំងនឹងភាពអសកម្មទាំងអស់នោះផងដែរ។ តួយ៉ាងយើងមានអត្ថបទរឿងភូមិតិរច្ឆានជាតឹកតាងស្រាប់។ ការជិះជាន់ និងគាបសង្កត់លើបញ្ហាពន្ធពីសំណាក់រេស៊ីដង់បារដេស បានធ្វើឱ្យប្រជាជនខ្មែរជាពិសេសអ្នកភូមិក្រាំងលាវមានការឈឺចាប់ជាខ្លាំង។ ក្នុងនោះអ្នកនិពន្ធបានបណ្តុះស្មារតីអ្នកអានតាមរយៈតួអង្គជួន នៅ ក៏ដូចជានាងនីនាងប៊ី ដើម្បីធ្វើការរើបំរះប្រឆាំងនឹងការគ្រប់គ្រងតាមបែបផ្តាច់ការមួយនេះ។ បើទោះបីជានៅចុងបញ្ចប់នៃរឿង អ្នកភូមិក្រាំងលាវពុំអាចរំដោះខ្លួនចេញបានពីនឹមអាណានិគមបារាំង តែយ៉ាងណាស្មារតីរបស់តួអង្គទាំងប៉ុន្មានក្នុងរឿងនេះ បានជះឥទ្ធិពលបន្តទៅដល់តួអង្គផ្សេងៗទៀតនៅក្នុងរឿងគូលីកំនែនជាដើម។ ការរើបំរះរបស់លឹម ឧបាសកខើចជើង នូដូង គ្រូរស់ក៏ដូចជាប្រជាជនខ្មែរពីគ្រប់តំបន់ បានធ្វើឱ្យសង្គមកម្ពុជាទទួលបានឯករាជ្យ សេរីភាពពេញលេញពីអាណានិគមជប៉ុន និងអាចរស់នៅប្រកបទៅដោយសុខសុភមង្គល។

ក្រៅអំពីការរើបំរះ ទាមទារឯករាជ្យ អ្នកនិពន្ធនៅក្នុងរឿងគ្រូបង្រៀនស្រុកស្រែ ក៏បានផ្តល់ជាយុទ្ធសាស្ត្រមួយចំនួនដែលប្រជាជនខ្មែរទាំងអស់អាចយកមកអនុវត្ត ដើម្បីធានាបាននូវភាពរីកចម្រើនក្នុងភូមិឃុំរបស់ខ្លួន[11] មានដូចជា៖

- ការពង្រឹងលើផ្នែកនយោបាយៈ ប្រជាជនទាំងអស់ត្រូវបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដោយខ្លួនឯង ទើបអាចធានាបាននូវការដឹកនាំដែលបម្រើផលប្រយោជន៍ដល់ប្រជារាស្ត្រជាធំ ចៀសវាងការកំណត់រើសដោយពួកអាណានិគម ដែលថ្នាក់ដឹកនាំទាំងនោះបម្រើឱ្យតែមហិច្ឆតាពួកអាណាព្យាបាលតែប៉ុណ្ណោះ។
- ផ្នែកសេដ្ឋកិច្ចៈ បង្កើតឱ្យមានសមាគមកសិករខ្មែរ ធ្វើការត្រួតពិនិត្យលើថ្លៃទំនិញ ចៀសវាងការបន្ថោកតម្លៃកសិផលរបស់ប្រជាកសិករពីសំណាក់ក្រុមឈ្មួញទាំងឡាយ។
- ផ្នែកសង្គមកិច្ចៈ បង្កើតឱ្យមានសមាគមយុវជន សមាគមស្ត្រី ធ្វើយ៉ាងណាបណ្តុះការចូលរួមពីសំណាក់ប្រជាជនគ្រប់ស្រទាប់ថ្នាក់ នៅក្នុងការបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធសង្គមនានាស្របទៅតាមតម្រូវការជាក់ស្តែង។

[11] សូមមើលរឿង *គ្រូបង្រៀនស្រុកស្រែ* អ៊ឹម ធុក ១៩៥៧

- ផ្នែកវប្បធម៌៖ អ្នកចេះច្រើនត្រូវជួយបង្រៀនអ្នកចេះតិច អ្នកចេះតិចត្រូវបង្រៀនអ្នកមិនចេះ ក្នុងនោះត្រូវបង្កើតឱ្យបណ្ណាល័យតាមភូមិស្រុកនានា ធ្វើយ៉ាងណាឱ្យប្រជាជនមានលទ្ធភាពនៅក្នុងការប្រើប្រាស់សៀវភៅ កាសែត ទស្សនាវដ្ដីដើម្បីអាចទទួលដឹងនូវបញ្ហាសង្គមផ្សេងៗបានឆាប់រហ័ស។ បន្ថែមពីលើនេះ ត្រូវបង្កើតឱ្យមានសាលារៀន និងឧបត្ថម្ភដល់គ្រូបង្រៀននៅក្នុងការបង្កើតកម្មវិធីសិក្សាអប់រំស្របតាមតម្រូវការជាក់ស្ដែងរបស់មនុស្សក្នុងសង្គម។

### គ.២.៣. បញ្ហាជំនឿ និងផ្នត់គំនិតចាស់គំរិល

អ្នកនិពន្ធបានផ្ដល់នូវវិប្បដិសារីជាច្រើនដល់តួអង្គម្ដាយទាវ ក្នុងរឿងទុំទាវ ក៏ដូចជាយាយនួននៅក្នុងរឿងផ្កាស្រពោន។ នោះគឺជាការដាក់ទោសទណ្ឌកម្មផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដែលយើងឃើញថាការប្រកាន់នូវទស្សនៈចាស់គំរិលឬជំនឿមិនសមហេតុផលនានាពុំមែនជារឿងល្អដល់មនុស្សសោះឡើយ។ នៅចុងបញ្ចប់នៃរឿងទុំទាវ អ្នកនិពន្ធសម្រេចឱ្យម្ដាយទាវត្រូវបាត់បង់កូនស្រីតែម្នាក់របស់ខ្លួន មិនខុសពីយាយនួនដែលត្រូវដេកឱបនូវអារម្មណ៍សោកស្ដាយចំពោះការបាត់បង់វិជាវីនោះទេ។ នេះជាមេរៀនមួយសម្រាប់ដាស់តឿនដល់ឪពុកម្ដាយទាំងឡាយ ត្រូវចេះផ្ដល់សិទ្ធសេរីភាពគ្រប់គ្រាន់ដល់កូនរបស់ខ្លួននៅក្នុងការសម្រេចធ្វើអ្វីដែលពួកគេស្រឡាញ់ និងពេញចិត្ត។ យើងសូមសរសើរចំពោះទស្សនៈរបស់លោកហ្លួងរតនសម្បត្តិ ក្នុងរឿងកុលាបប៉ៃលិន ក៏ដូចជាលោកសួន នៅក្នុងរឿងសូផាត ដែលលោកទាំងពីរនេះហៅថាជាមនុស្សដែលមានទស្សនៈជឿនលឿន នៅក្នុងការរៀបចំទុកដាក់កូនចៅប្រកបទៅដោយភាពរីករាយ និងសេចក្ដីសុខ។

## ៤. សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាវិភាគរួចមក យើងអាចធ្វើការសន្និដ្ឋានបានថា ស្នាដៃអក្សរសិល្ប៍ខ្មែរនីមួយៗពិតជាប្រកបទៅដោយគុណតម្លៃយ៉ាងវិសេសវិសាល។ ក្រៅអំពីមុខងារកម្សាន្ត អក្សរសិល្ប៍បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្ដល់នូវពុទ្ធិចំណេះដឹង ការអប់រំ (សីលធម៌ គុណធម៌ ចរិយាធម៌ បញ្ញាស្មារតី សិល្បសញ្ចេតនា) ការផ្សព្វផ្សាយនូវវប្បធម៌ជាតិ ក៏ដូចជាផ្ដល់នូវគន្លឹះនៅក្នុងការដោះស្រាយបញ្ហានានាដែលកើតមាននៅក្នុងសង្គមរស់នៅរបស់មនុស្សផងដែរ។ ទាំងអស់នេះ សុទ្ធសឹងតែជាមុខងារសំខាន់ ឆ្លុះបញ្ចាំងឱ្យឃើញនូវតួនាទីរបស់ស្នាដៃអក្សរសិល្ប៍នៅក្នុងសង្គម។

បើយោងតាមការវិភាគខ្លឹមសារប៉ុន្មានទំព័រនេះ ពិតជាពុំអាចឱ្យយើងស្វែងយល់បានគ្រប់ជ្រុងជ្រោយនូវអត្ថន័យ និងតម្លៃនៃអត្ថបទស្នាដៃអក្សរសិល្ប៍បានអស់នោះឡើយ។ តែយ៉ាងហោចណាស់វាក៏ជាអត្ថរសមួយដ៏សំខាន់ ដែលអាចផ្ដល់ជាទុនពុទ្ធិដ៏សម្បូរបែបដល់កូនខ្មែរ ក៏ដូចជាអ្នកសិក្សាស្នាដៃអក្សរសិល្ប៍ជំនាន់ក្រោយឱ្យបានជ្រួតជ្រាប និងយកទុកជាចំណេះដឹងសម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយបន្តទៀត។ យ៉ាងណាមិញ ការសិក្សាមួយនេះក៏អាចជាទុនចូលរួមនៅក្នុងការដាស់អារម្មណ៍កុលបុត្រកុលធីតាខ្មែរឱ្យយកចិត្តទុកដាក់លើការអាន សមស្របនឹងពាក្យស្លោកដែលក្រសួងអប់រំបានលើកឡើងថា "**អំណានជាកំណប់ទង្វាមហាសាល**"។

**ឯកសារពិគ្រោះ**


១. ញ៉ុក ថែម *រឿង កុលាបប៉ៃលិន* ១៩៣៦

២. នូ ហាច *រឿង ផ្កាស្រពោន* ១៩៤៨

៣. អ៊ឹម ប៉ុក *រឿង គ្រូបង្រៀនស្រុកស្រែ* ១៩៥៧

៤. ភិក្ខុសោម *រឿង ទុំទាវ* ១៩១៥

៥. សួន សុរិន្ទ *រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់* ១៩៦០

៦. នូ ហាច *រឿង មាលាដួងចិត្ត* ១៩៤១

៧. ឡៅក អំ និងឌឹក គាម *រឿង ភូមិតិរច្ឆាន* ១៩៧១

៨. អ៊ឹម ប៉ុក*រឿង គូលីកំនែន* ១៩៥៦

៩. សម្តេចសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរ* ១៩៦៧

១០. ត្រឹង ងា *អរិយធម៌ខ្មែរ* ១៩៧៥

១១. បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន *វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ* ២០១៩

១២. ធយ យីហ៊ាងនិងយ៉ង់ ធី *អត្តសញ្ញាណប្រទេសខ្មែរ* ២០០០

១៣. ជុំ ឃុនសុជាតា *ប្រវត្តិអក្សរសិល្ប៍*២០១៣

១៤. ទេស ហាវ *អរិយធម៌ខ្មែរ*២០១២

១៥. គីម សួរ *ទ្រឹស្តីអក្សរសិល្ប៍* ២០១២

១៦. ជ័យ ចាប និងពន់ ឆាយ *ទ្រឹស្តីអក្សរសិល្ប៍* ១៩៩៤

១៧. ក្រសួងអប់រំ *អក្សរសិល្ប៍ខ្មែរថ្នាក់ទី៨* ដោយ អ៊ីវ ចុង ១៩៨៥

១៨. នក ហង្សផល្លា *ភាពវិជ្ជមានក្នុងអក្សរសិល្ប៍ខ្មែរ*២០១០